# របាយការណ៍សង្ខេបស្តីពីការវាយតម្លៃបឋម
# លើផលប៉ះពាល់សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ
# របស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
# ក្រសួងអប់រំ យុវជន និងកីឡា

## សេចក្តីផ្តើម

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកប ដោយចីរភាពនិងសមធម៌ ការកែលម្អជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដើម្បី ប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

ដើម្បីចូលរួមសម្រេចបាននូវចក្ខុវិស័យនេះ ពិតណាស់គឺត្រូវពឹងផ្អែកលើកត្តាធនធានមនុស្សជា ចម្បង។ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងពេលចំពោះមុខ និងសម្រាប់អនាគត។

ការបង្កើតឱ្យមាននូវសហគមន៍សេដ្ឋកិច្ចអាស៊ាននៅក្នុងសមាគមអាស៊ាន បានបង្ហាញច្បាស់អំពី ដំណើរវិវដ្តនៃសមាហរណកម្មតំបន់ និងសកលលោក។ ដូចនេះ ដើម្បីដណ្តើមឧត្តមភាពប្រកួតប្រជែងនិង លើកកម្ពស់កាលានុវត្តភាពរបស់កម្ពុជាជាមួយប្រទេសជិតខាង ទាមទារឱ្យមានការបណ្តុះបណ្តាលសិស្ស និស្សិត និងពលករខ្មែរ ឱ្យមានជំនាញច្បាស់លាស់និងមានផលិតភាពខ្ពស់ តាមរយៈការពង្រឹងគុណភាព នៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងអប់រំឱ្យបានកាន់តែរឹងមាំនិងកាន់តែមានប្រសិទ្ធភាព គឺជាចំណែក មួយដ៏សំខាន់ក្នុងការពង្រឹងគុណភាពនិងប្រសិទ្ធភាពអប់រំ។ នៅថ្នាក់ជាតិ រចនាសម្ព័ន្ធគ្រប់គ្រងអប់រំត្រូវបាន កែប្រែជាបន្តបន្ទាប់ ហើយបច្ចុប្បន្ននេះកំពុងអនុវត្តតាមអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦។ រីឯ នៅថ្នាក់ក្រោមជាតិវិញ រចនាសម្ព័ន្ធគ្រប់គ្រងអប់រំត្រូវបានអនុវត្តតាមសេចក្តី ណែនាំលេខ ៣៧៦៧ អយក.សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩។ ផ្អែកលើសេចក្តីណែនាំនេះ រចនាសម្ព័ន្ធ គ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡា ត្រូវបានបែងចែកជា ០៣ ប្រភេទ គឺៈ មន្ទីរធំដែលមាន១១ ការិយាល័យ មន្ទីរមធ្យមដែលមាន០៩ការិយាល័យ និងមន្ទីរតូចដែលមាន០៧ការិយាល័យ។ ប៉ុន្តែក្នុងការ អនុវត្តជាក់ស្តែងវិញ នៅតាមមន្ទីរមួយចំនួនពុំទាន់មានចំនួនការិយាល័យស្របតាមការកំណត់នេះឡើយ។ ម្យ៉ាងវិញទៀត នៅថ្នាក់ជាតិបានធ្វើការបែងចែកជាអនុវិស័យចំនួន៧ ក្នុងនោះរួមមានៈ អនុវិស័យការអប់រំ កុមារតូច អនុវិស័យការអប់រំបឋមសិក្សា អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស អនុវិស័យ ការអប់រំឧត្តមសិក្សា អនុវិស័យការអប់រំក្រៅប្រព័ន្ធ អនុវិស័យការអភិវឌ្ឍយុវជន និងអនុវិស័យការអប់រំកាយ និងកីឡា។ ប៉ុន្តែ នៅតាមមន្ទីរខ្លះ បានប្រើប្រាស់ការិយាល័យមួយឱ្យអនុវត្តការងារអនុវិស័យចំនួនពីរ។ ឧទាហរណ៍: ការិយាល័យបឋមនិងមត្តេយ្យសិក្សា ត្រូវអនុវត្តការងាររបស់អនុវិស័យចំនួនពីរនៅថ្នាក់ជាតិ គឺអនុវិស័យអប់រំកុមារតូច និងអនុវិស័យបឋមសិក្សា។

តាមរយៈនេះ បង្ហាញឱ្យឃើញថា រចនាសម្ព័ន្ធគ្រប់គ្រងនៅតាមមន្ទីរអប់រំ យុវជន និងកីឡា ពុំមានលក្ខណៈឆ្លើយតបទៅនឹងការកំណត់របស់សេចក្តីណែនាំលេខ៣៧៦៧ឡើយ។ម្យ៉ាងវិញទៀតរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់មន្ទីរនេះទៀតសោត ក៏ពុំទាន់ឆ្លើយតបទៅនឹងការបែងចែកឱ្យមានការទទួលខុសត្រូវតាមអនុវិស័យដូចដែលថ្នាក់ជាតិបានកំណត់ឡើយ ហើយបញ្ហានេះអាចនឹងជះឥទ្ធិពលទៅលើតម្រូវការជាក់ស្តែងក្នុងការផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋ។ ដូចនេះ ជាការចាំបាច់ដែលក្រសួងគួរធ្វើការពិនិត្យឡើងវិញនិងកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡា សារជាថ្មី តាមរយៈការរៀបចំឱ្យមានលិខិតបទដ្ឋានគតិយុត្តរួមមួយជាគោល។

## ការកំណត់បញ្ហា

បើគិតមកដល់បច្ចុប្បន្ន សេចក្តីណែនាំលេខ ៣៧៦៧ នេះ គឺមានអាយុកាលជិត ១៧ ឆ្នាំហើយ ដែលរចនាសម្ព័ន្ធគ្រប់គ្រងនេះ ហាក់ពុំសូវមានភាពឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍក្នុងវិស័យអប់រំឡើយ។ ជាក់ស្តែង តាមរយៈការអនុវត្តនូវសេចក្តីណែនាំនេះ នាពេលកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា សង្កេតឃើញមាននូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

**១-បញ្ហាប្រសិទ្ធភាពការងារៈ** និន្នាការប្រែប្រួលនៃចំនួនអ្នកទទួលសេវាអប់រំ និងអ្នកផ្តល់សេវាអប់រំ ពីមួយឆ្នាំទៅមួយឆ្នាំ បានធ្វើឱ្យប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំក៏មានការប្រែប្រួលដែរ។ ការងារជំនាញខ្លះ ត្រូវបានប្រមូលផ្តុំក្នុងការិយាល័យតែមួយ ធ្វើឱ្យចរន្តនៃការផ្តល់សេវា និងចរន្តនៃការងារផ្នែកខ្លះ មិនអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកផ្តល់សេវានិងអ្នកទទួលសេវា។ ម្យ៉ាងវិញទៀត មន្ទីរមួយចំនួនគួរតែត្រូវបានប្រែក្លាយពីប្រភេទមួយទៅជាប្រភេទមួយទៀត ប៉ុន្តែមិនទាន់បានធ្វើការប្រែក្លាយនៅឡើយ។

**២-ទំនួលខុសត្រូវច្រើនៈ** ក្រសួងអប់រំ យុវជន និងកីឡា បច្ចុប្បន្នកំពុងដំណើរការផ្ទេរមុខងារ នៃអនុវិស័យ ០៣ ទៅឱ្យរដ្ឋបាល ក្រុង ស្រុក គឺមុខងារការអប់រំកុមារតូច បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ការផ្ទេរមុខងារនេះនឹងនាំឱ្យមន្ទីរកាន់តែមានទំនួលខុសត្រូវច្រើនជាងមុននៅចំពោះមុខរដ្ឋបាលរាជធានី ខេត្ត ផង និងក្រសួងផង ក្នុងនាមជាសេនាធិការ។ អនុវត្តតាមរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ន មន្ទីរអាចនឹងមានសម្ពាធក្នុងការទទួលខុសត្រូវលើការងារដែលក្រសួងផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងខណៈពេលដែលមន្ទីរមួយចំនួន មិនទាន់មានរចនាសម្ព័ន្ធឆ្លើយតបទៅនឹងអនុវិស័យដែលបានផ្ទេរ។ ដោយឡែកមន្ទីរមួយចំនួនទៀតមានរចនាសម្ព័ន្ធឆ្លើយតបទៅនឹងអនុវិស័យដែលបានផ្ទេរ ប៉ុន្តែរចនាសម្ព័ន្ធនេះមិនស្របតាមសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ស្តីពីមុខងារ ភារកិច្ចនៃរចនាសម្ព័ន្ធរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងឡើយ។

**៣-រចនាសម្ព័ន្ធរបស់មន្ទីរៈ** រចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរមួយចំនួននាពេលបច្ចុប្បន្នមិនស្របតាមសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ឡើយ ដោយហេតុថា មន្ទីរខ្លះបានទទួលការអនុញ្ញាតឱ្យបង្កើតការិយាល័យថ្មីបន្ថែម ដែលប្រការនេះ បាននាំឱ្យស្មារតីនៃសេចក្តីណែនាំលេខ ៣៧៦៧ ត្រូវបាត់បង់សុពលភាពបន្តិចម្តងៗ។

## គោលបំណង

ការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ធ្វើឡើងក្នុងគោលបំណងធានាប្រសិទ្ធភាពការងាររបស់មន្ទីរ សំដៅលើកកម្ពស់គុណភាពអប់រំឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គម។

## ជម្រើស

ដើម្បីដោះស្រាយបញ្ហាដូចមានលើកឡើងខាងលើ ការិយាល័យវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋាននៃនាយកដ្ឋាននីតិកម្ម បានលើកយកជម្រើសចំនួនបី មកធ្វើការសិក្សាវិភាគដូចខាងក្រោម ៖

**១.ជម្រើសទី១ ៖** រក្សាស្ថានភាពដើម ដោយបន្តអនុវត្តសេចក្តីណែនាំលេខ ៣៧៦៧ អយ ក.សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរមាន ០៣ ប្រភេទ គឺមន្ទីរធំដែលមាន១១ការិយាល័យ មន្ទីរមធ្យមដែលមាន០៩ការិយាល័យ និងមន្ទីរតូចដែលមាន០៧ ការិយាល័យ។

**២.ជម្រើសទី២ ៖** សេចក្តីព្រាងប្រកាសថ្មី ដែលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរមានដូចគ្នាទាំងអស់ គឺមាន ១២ការិយាល័យ។

**៣.ជម្រើសទី៣ ៖** សេចក្តីព្រាងប្រកាសថ្មី ដែលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរមាន ០២ ប្រភេទ គឺមន្ទីរធំដែលមាន១២ការិយាល័យ និងមន្ទីរតូចដែលមាន១០ការិយាល័យ។

## ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគព្វកិច្ច និងផលចំណេញ

**១.ជម្រើសទី១៖** រក្សាស្ថានភាពដើម ដោយបន្តអនុវត្តសេចក្តីណែនាំលេខ ៣៧៦៧ អយក.សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ គឺពុំមានបន្ទុកចំណាយគួរឱ្យកត់សម្គាល់ឡើយ។

**២.ជម្រើសទី២៖** សេចក្តីព្រាងប្រកាសថ្មី ដែលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរមានដូចគ្នាទាំងអស់ គឺមាន ១២ ការិយាល័យ ត្រូវបង្កើនបន្ទុកចំណាយសរុបប្រហែល **៤ ៧៧៩ ៦៥៦ ៨៥៩** រៀល ស្មើនឹង **១ ១៩៤ ៩១៤** ដុល្លារសហរដ្ឋអាមេរិក។

**៣.ជម្រើសទី៣៖** សេចក្តីព្រាងប្រកាសថ្មី ដែលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរមាន ០២ ប្រភេទ គឺមន្ទីរធំដែលមាន១២ការិយាល័យ និងមន្ទីរតូច ដែលមាន១០ការិយាល័យ ត្រូវបង្កើនបន្ទុកចំណាយសរុបចំនួន **២ ៨០៥ ២៤៦ ៦០៧** រៀល ស្មើនឹង **៧០១ ៣១២** ដុល្លារសហរដ្ឋអាមេរិក។

## កិច្ចពិគ្រោះយោបល់បឋម

កិច្ចពិគ្រោះយោបល់ត្រូវបានធ្វើឡើងដូចតទៅ ៖

- ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (MoEYS–RIA TEAM) បានធ្វើការប្រជុំនិងពិគ្រោះយោបល់ក្នុងនាយកដ្ឋាននីតិកម្ម។
- ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តនៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS–RIA TEAM) បានធ្វើការប្រជុំនិងពិគ្រោះយោបល់ចំនួន៤លើកជាមួយក្រុម ORIA-ECOSSOC នៃទីស្តីការគណៈរដ្ឋមន្ត្រី។

- ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តនៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS–RIA TEAM) បានធ្វើការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តសៀមរាប។

## សន្និដ្ឋាន

ផ្អែកលើការវិភាគអំពីចំណាយនៃជម្រើសទាំងបីខាងលើនេះបានបង្ហាញថា ជម្រើសទី១ មានការចំណាយមួយចំនួនដែលមិនអាចគណនាជាតួលេខបាន ប៉ុន្តែជម្រើសទី២ មានការចំណាយលើកដំបូងចំនួន **៦៣ ៣៦០ ០០០ រៀល** ស្មើនឹង **១៥ ៨៤០** ដុល្លារសហរដ្ឋអាមេរិក រីឯជម្រើសទី៣ មានការចំណាយលើកដំបូងចំនួន **២៩ ០៤០ ០០០ រៀល** ស្មើនឹង **៧ ២៦០** ដុល្លារសហរដ្ឋអាមេរិក។ បើប្រៀបធៀបជម្រើសទាំងបីនេះ ឃើញថាជម្រើសទី១ ការចំណាយ និងផលចំណេញ ធ្វើឱ្យមានការពិបាកក្នុងការអភិវឌ្ឍការគ្រប់គ្រងរចនាសម្ព័ន្ធឱ្យមានភាពរីកចម្រើននិងឆ្ពោះទៅមុខ រីឯជម្រើសទី២ និងទី៣ មានផលចំណេញស្រដៀងគ្នា និងមានភាពខុសគ្នារវាងទឹកប្រាក់នៃការចំណាយ ដោយការចំណាយរបស់ជម្រើសទី៣ ទាបជាងជម្រើសទី២។

ដូច្នេះ **ជម្រើសទី៣៖** សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមាន ០២ ប្រភេទ គឺមន្ទីរធំ និងមន្ទីរតូច គួរត្រូវបានពិចារណាជ្រើសរើស។

លទ្ធផលនៃវាយតម្លៃបឋមនេះ អាចទទួលយកបានដោយមិនចាំបាច់ធ្វើការវាយតម្លៃបន្តទៀតទេ។

## ការអនុវត្ត និងការពិនិត្យតាមដាន

នាយកដ្ឋានជំនាញដែលពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្សព្វផ្សាយប្រកាសនេះដល់បុគ្គលិកអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ទាំងអស់ ដើម្បីឱ្យមានការអនុវត្តស្របតាមតួនាទី និងភារកិច្ច ដែលបានកំណត់ក្នុងប្រកាស និងតាមដានត្រួតពិនិត្យវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តប្រកាសនេះ។

ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តត្រូវពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់ជាក់ស្តែងនៃការអនុវត្ត និងលើកជាយោបល់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច។ ប្រកាសនេះនឹងធ្វើការកែសម្រួលឡើងវិញ ប្រសិនបើក្រសួងមានឆន្ទៈក្នុងការកែសម្រួល។

# ការវាយតម្លៃបឋមលើផលប៉ះពាល់
# សេចក្តីព្រាងប្រកាស ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ
# របស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
# ក្រសួងអប់រំ យុវជន និងកីឡា

លេខយោង:

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦

កាលបរិច្ឆេទបញ្ចប់: ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

សំណើបញ្ញត្តិកម្មនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ក្នុងគោលដៅរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង កំណត់តួនាទី និងភារកិច្ច ដើម្បីធានាប្រសិទ្ធភាពការងាររបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឆ្លើយតបទៅនឹងកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលក្នុងវិស័យអប់រំ។

តាមរយៈសំណើបញ្ញត្តិកម្មនេះ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង ០២ (ពីរ) ប្រភេទគឺៈ

ក. ខេត្តធំ មានការិយាល័យ ចំណុះចំនួន ១២ (ដប់ពីរ)

ខ. ខេត្តតូច មានការិយាល័យ ចំណុះចំនួន ១០ (ដប់)

សំណើបញ្ញត្តិកម្មនេះមានវិសាលភាពអនុវត្តចំពោះមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងជាសេនាធិការរបស់គណៈអភិបាលរាជធានី ខេត្ត លើការងារអប់រំ។

## ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

## ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យៈ

☐សេដ្ឋកិច្ច ☐សង្គមកិច្ច ☐បរិស្ថាន ☑អប់រំ ☐ផ្សេងៗ

## ១. ការកំណត់បញ្ហា

**១-បញ្ហាប្រសិទ្ធភាពការងារ ៖** និន្នាការប្រែប្រួលនៃចំនួនអ្នកទទួលសេវាអប់រំ និងអ្នកផ្តល់សេវាអប់រំពីមួយឆ្នាំទៅមួយឆ្នាំ បានធ្វើឱ្យប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំក៏មានការប្រែប្រួលដែរ។ ការងារជំនាញមួយចំនួនត្រូវបានប្រមូលផ្តុំក្នុងការិយាល័យតែមួយ ធ្វើឱ្យចរន្តនៃការផ្តល់សេវា និងចរន្តនៃការងារផ្នែកខ្លះ មិនអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកផ្តល់សេវានិងអ្នកទទួលសេវា។ ម្យ៉ាងវិញទៀត មន្ទីរមួយចំនួនគួរតែត្រូវបានប្រែក្លាយពីប្រភេទមួយទៅជាប្រភេទមួយទៀត ប៉ុន្តែមិនទាន់បានធ្វើការប្រែក្លាយនៅឡើយ។
**២-ទំនួលខុសត្រូវច្រើន ៖** ក្រសួងអប់រំ យុវជន និងកីឡា បច្ចុប្បន្នកំពុងដំណើរការផ្ទេរមុខងារ នៃអនុវិស័យ

០៣ ទៅឱ្យរដ្ឋបាល ក្រុង ស្រុក គឺមុខងារការអប់រំកុមារតូច បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ការផ្ទេរមុខងារនេះនឹងនាំឱ្យមន្ទីរកាន់តែមានទំនួលខុសត្រូវច្រើនជាងមុននៅចំពោះមុខរដ្ឋបាលរាជធានី ខេត្ត ផង និងក្រសួងផង ក្នុងនាមជាសេនាធិការ។ អនុវត្តតាមរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ន មន្ទីរអាចនឹងមានសម្ពាធក្នុងការទទួលខុសត្រូវលើការងារដែលក្រសួងផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងខណៈពេលដែលមន្ទីរមួយចំនួន មិនទាន់មានរចនាសម្ព័ន្ធឆ្លើយតបទៅនឹងអនុវិស័យដែលបានផ្ទេរ។ ដោយឡែកមន្ទីរមួយចំនួនទៀតមានរចនាសម្ព័ន្ធឆ្លើយតបទៅនឹងអនុវិស័យដែលបានផ្ទេរ ប៉ុន្តែរចនាសម្ព័ន្ធនេះមិនស្របតាមសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ស្តីពីមុខងារ ភារកិច្ចនៃរចនាសម្ព័ន្ធរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ឡើយ។

**៣-រចនាសម្ព័ន្ធរបស់មន្ទីរ ៖** រចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរមួយចំនួននាពេលបច្ចុប្បន្ន មិនស្របតាមសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ឡើយ ដោយហេតុថា មន្ទីរមួយចំនួនបានទទួលការអនុញ្ញាតឱ្យបង្កើតនូវការិយាល័យថ្មីបន្ថែម ដែលប្រការនេះបាននាំឱ្យស្មារតីនៃសេចក្តីណែនាំលេខ ៣៧៦៧ ត្រូវបាត់បង់សុពលភាពបន្តិចម្តងៗ។

តាមរយៈនេះ បង្ហាញឱ្យឃើញថា រចនាសម្ព័ន្ធគ្រប់គ្រងនៅតាមមន្ទីរអប់រំ យុវជន និងកីឡាពុំមានលក្ខណៈឆ្លើយតបទៅនឹងការកំណត់របស់សេចក្តីណែនាំលេខ៣៧៦៧ឡើយ។ ម្យ៉ាងវិញទៀតរចនាសម្ព័ន្ធនៅថ្នាក់មន្ទីរនេះទៀតសោត ក៏ពុំទាន់ឆ្លើយតបទៅនឹងការបែងចែកឱ្យមានការទទួលខុសត្រូវតាមអនុវិស័យដូចដែលថ្នាក់ជាតិបានកំណត់ឡើយ ហើយបញ្ហានេះអាចនឹងជះឥទ្ធិពលទៅលើតម្រូវការជាក់ស្តែងក្នុងការផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋ។ ដូចនេះ ជាការចាំបាច់ដែលក្រសួងគួរធ្វើការពិនិត្យឡើងវិញនិងកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡា សាជាថ្មីតាមរយៈការរៀបចំឱ្យមានលិខិតបទដ្ឋានគតិយុត្តរួមមួយជាគោល។

១.គ សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។

-សេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីមុខងារ ភារកិច្ចនៃរចនាសម្ព័ន្ធរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង បានកំណត់ប្រភេទមន្ទីរមាន០៣ (បី)ប្រភេទគឺ៖ ១.ខេត្តធំមាន១១ (ដប់មួយ) ការិយាល័យ ២.ខេត្តមធ្យមមាន០៩ (ប្រាំបួន) ការិយាល័យ ៣.ខេត្តតូចមាន ០៧ (ប្រាំពីរ) ការិយាល័យ។ ដូចនេះ ពេលមានការស្នើសុំបង្កើតការិយាល័យបន្ថែមធ្វើឱ្យចំនួនការិយាល័យកើនឡើងផ្ទុយពីសេចក្តីណែនាំនេះ។ ម្យ៉ាងវិញទៀត សេចក្តីណែនាំនេះ បានកំណត់យ៉ាងច្បាស់ពីចំណាត់ថ្នាក់នៃប្រភេទខេត្ត ប៉ុន្តែនាពេលបច្ចុប្បន្ននេះ ស្ថានភាពបុគ្គលិកនៅក្នុងខេត្តមួយចំនួនមានការផ្លាស់ប្តូរ ជាមូលហេតុធ្វើឱ្យការបន្តអនុវត្តសេចក្តីណែនាំ មិនស្របតាមស្ថានភាពបច្ចុប្បន្ន។

-សារាចរណែនាំលេខ ០៧ អយក-សរណន ស្តីពីការគ្រប់គ្រង មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង នៅតែបន្តអនុវត្ត ព្រោះសារាចរនេះ បានចែងពីភារកិច្ច និងសិទ្ធ របស់ថ្នាក់គ្រប់គ្រងមន្ទីរ មិនមានអ្វីប្រតិឃាតជាមួយនឹងប្រកាសនេះឡើយ។

-ប្រកាសលេខ ៣៧៤ អយក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីការបង្កើតការិយាល័យផែនការនិងគ្រប់គ្រងជំនួយនៅក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡា ប្រភេទមធ្យម និងប្រភេទខេត្តតូច

ការអនុវត្តប្រកាសនេះបានផ្ទុយទៅនឹងសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រង់ចំណុចនៃការកំណត់ពីចំនួនការិយាល័យ។

-ប្រកាសលេខ ១៩០ អយក.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបំបែកការិយាល័យបឋម និងមត្តេយ្យសិក្សាទៅជាការិយាល័យអប់រំកុមារតូច និងការិយាល័យបឋមសិក្សា ការអនុវត្តប្រកាសនេះបានផ្ទុយទៅនឹងសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រង់ចំណុចនៃការកំណត់ពីចំនួនការិយាល័យ។ ប៉ុន្តែប្រកាសនេះ ត្រូវបានអនុវត្តឱ្យស្របតាមនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រដ្ឋាភិបាលលើវិស័យអប់រំ ដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងដំណើរការផ្ទេរមុខងារដែលជាអនុវិស័យ ០៣ ទៅឱ្យរដ្ឋបាល ក្រុង ស្រុក គឺមុខងារការអប់រំកុមារតូច បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ទៅឱ្យថ្នាក់ក្រោមជាតិ។

-ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ គឺគ្រាន់តែជាច្បាប់រួមមួយដែលគ្រប់ដណ្តប់គ្រប់ទិដ្ឋភាពពាក់ព័ន្ធនឹងវិស័យអប់រំ ដោយឡែកច្បាប់នេះក៏ចង្អុលបង្ហាញផងដែរអំពីឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងការអប់រំ។

-អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺជាអនុក្រឹត្យមួយដែលចែងជារួមដើម្បីធ្វើការកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងរចនាសម្ព័ន្ធគ្រប់គ្រងទាំងអង្គភាពថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន។

១. ឃ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?

សំណើបញ្ញត្តិកម្មនេះ មិនមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង (ជាលក្ខណៈពាណិជ្ជកម្ម) ឡើយ។

## ២. គោលបំណង

ការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ធ្វើឡើងក្នុងគោលបំណងធានាប្រសិទ្ធភាពការងាររបស់មន្ទីរ សំដៅលើកកម្ពស់គុណភាពអប់រំឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គម។

## ៣. ជម្រើស

១.រក្សាស្ថានភាពដើមៈ បន្តអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់

២.សំណើប្រកាសថ្មីដែលមានរចនាសម្ព័ន្ធដូចគ្នាទាំងអស់

៣.សំណើប្រកាសថ្មី ដែលរចនាសម្ព័ន្ធមាន ០២ ប្រភេទ គឺមន្ទីរធំ និងមន្ទីរតូច

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាកិច្ច និងផលចំណេញ

៤.១ ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១ៈ បន្តអនុវត្តសេច | - គ្មាន | - គ្មាន |

| | | |
|---|---|---|
| ក្តីណែនាំលេខ ៣៧៦៧ អយក-សណន ដែលមានស្រាប់ | | |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមានដូចគ្នាទាំងអស់ | - បន្ទុកចំណាយលើការរៀបចំសំណើបញ្ញត្តិកម្មថ្មីប្រហែល **៩ ៥៧៥ ៩១៦** រៀល<br>- បន្ទុកចំណាយលើការពិគ្រោះយោបល់ប្រហែល **៦៦ ៦៦៨ ៣៣៩** រៀល<br>- បន្ទុកចំណាយលើការទិញសម្ភារការិយាល័យប្រហែល **៣ ៧៣២ ៦៣៨ ៥០០** រៀល<br>- បន្ទុកចំណាយលើប្រាក់បំណាច់មុខងារអ្នកដែលត្រូវតែងតាំងប្រហែល **៧២ ៨៦៤ ០០០** រៀល<br>- បន្ទុកចំណាយលើការផ្សព្វផ្សាយប្រហែល **១០៤ ២៧២ ០០០** រៀល<br>**បន្ទុកចំណាយសរុបប្រហែល ៤ ៧៧៩ ៦៥៦ ៨៥៩ រៀល** ស្មើនឹង **១ ១៩៤ ៩១៤ $** | - គ្មាន |
| ជម្រើសទី៣៖ សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមាន ០២ ប្រភេទគឺមន្ទីរធំ និងមន្ទីរតូច | - បន្ទុកចំណាយលើការរៀបចំសំណើបញ្ញត្តិកម្មថ្មីប្រហែល **៩ ៥៧៥ ៩១៦** រៀល<br>- បន្ទុកចំណាយលើការពិគ្រោះយោបល់ប្រហែល **៦៦ ៦៦៨ ៣៣៩** រៀល<br>- បន្ទុកចំណាយលើការទិញសម្ភារការិយាល័យប្រហែល **១ ៧១០ ៧៩២ ៦០០** រៀល<br>- បន្ទុកចំណាយលើប្រាក់បំណាច់មុខងារអ្នកដែលត្រូវ | -គ្មាន |

| | | |
|---|---|---|
| | តែងតាំងប្រហែល **២៩ ០៤០ ០០០** រៀល<br>- បន្ទុកចំណាយលើការផ្សព្វផ្សាយប្រហែល **១០៤ ២៧២ ០០០** រៀល<br>- **បន្ទុកចំណាយសរុបប្រហែល ២ ៨០៥ ២៤៦ ៦០៧ រៀល** ស្មើនឹង **៧០១ ៣១២ $** | |

៤.២ ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ដែលមានស្រាប់ | - រក្សាស្ថានភាពដើម។<br>- ផលចំណេញបានតិចតួចដោយសារ៖<br>• មិនត្រូវបានបង្កើនបន្ទុកចំណាយ<br>• មិនប៉ះពាល់ដល់ទឹកចិត្តបុគ្គលិកដែលពេញចិត្តនឹងបំពេញការងារតាមរចនាសម្ព័ន្ធចាស់<br>• មិនខាតពេលក្នុងការផ្សព្វផ្សាយ បណ្តុះបណ្តារៀបចំរចនាសម្ព័ន្ធថ្មី | - គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមានដូចគ្នាទាំងអស់ | - កំណត់រចនាសម្ព័ន្ធគ្រប់គ្រងតួនាទី និងភារកិច្ចរបស់ការិយាល័យ មានភាពច្បាស់លាស់ឆ្លើយតបទៅនឹងទំហំការងារ និងមានការឯកភាពគ្នាទូទាំងប្រទេស<br>- បែងចែកទំនួលខុសត្រូវរបស់ការិយាល័យនីមួយៗដាច់ពីគ្នា និងកាន់តែខ្លាំងជាងមុន<br>- មានទំនាក់ទំនងការងារល្អ | - គ្មាន |

| | | |
|---|---|---|
| | - ចន្លុះការងារគោរពតាមឋានានុក្រមច្បាស់លាស់ | |
| ជម្រើសទី៣៖ សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមាន ០២ ប្រភេទគឺ មន្ទីរធំ និងមន្ទីរតូច | - រចនាសម្ព័ន្ធគ្រប់គ្រង និងទំហំការងារមានភាពឆ្លើយតបទៅនឹងប្រភេទរបស់មន្ទីរ<br>- មានទំនួលខុសត្រូវការងារស្របតាមរចនាសម្ព័ន្ធនៃប្រភេទមន្ទីរ | - |

៤.៣ វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តសេចក្តីណែនាំលេខ ៣៧៦៧ អយក-សណន ដែលមានស្រាប់ | | | |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមានដូចគ្នាទាំងអស់ | | | |
| ជម្រើសទី៣៖ សេចក្តីព្រាងប្រកាសថ្មីដែលរចនាសម្ព័ន្ធរបស់មន្ទីរមាន ០២ ប្រភេទគឺ មន្ទីរធំ និងមន្ទីរតូច | | | |

## ៥. កិច្ចពិគ្រោះយោបល់

- ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (MoEYS–RIA TEAM) បានធ្វើការប្រជុំនិងពិគ្រោះយោបល់ក្នុងនាយកដ្ឋាននីតិកម្ម។

- ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តនៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS–RIA TEAM) បានធ្វើការប្រជុំនិងពិគ្រោះយោបល់ចំនួន៤លើកជាមួយក្រុម ORIA-ECOSSOC នៃទីស្តីការគណៈរដ្ឋមន្ត្រី។

- ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តនៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS–RIA TEAM) បានធ្វើការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តសៀមរាប។

## ៦. សន្និដ្ឋាន

តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

| |
|---|
| បញ្ញត្តិកម្មដែលស្នើឡើងនេះ មិនមានផលប៉ះពាល់ដល់ធុរកិច្ចឡើយ ប៉ុន្តែបញ្ញត្តិកម្មនេះនឹងផ្តល់នូវផលវិជ្ជមានក្នុងការពង្រឹងគុណភាព ប្រសិទ្ធភាពរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ ដោយមានការទទួលខុសត្រូវច្បាស់លាស់ និងធានាបាននូវគុណភាព ប្រសិទ្ធភាពលើការអនុវត្តការងារក្នុងវិស័យអប់រំ។ ដោយផ្អែកលើការវាយតម្លៃផលប៉ះពាល់ ជម្រើសទី៣ គួរត្រូវបានជ្រើសរើស។ |

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ

៧.១ តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| បើសិនជាសំណើរៀបចំប្រកាសថ្មីនេះ ទោះតាមជម្រើសណាមួយក៏ដោយ ពុំទាមទារឱ្យមានការចុះពិនិត្យតាមដាននោះទេ គ្រាន់តែមន្ទីរធ្វើរបាយការណ៍អំពីការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់ខ្លួនមកក្រសួងអប់រំ យុវជន និងកីឡា ជាការស្រេច ។ |

៧.២.តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះ គួរត្រូវបានពិនិត្យឡើងវិញ / តាមដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| ក្នុងករណីសំណើប្រកាសថ្មីត្រូវបានជ្រើសរើស ប្រកាសនេះពុំទាមទារឱ្យមានការត្រួតពិនិត្យឡើងវិញនោះទេ ប៉ុន្តែយើងនឹងធ្វើការកែសម្រួលឡើងវិញ ប្រសិនបើរាជរដ្ឋាភិបាលមានឆន្ទៈក្នុងការកែសម្រួល។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា | ឯកឧត្តម ស៊ិន សេងហុក | ប្រធាន | | | |
| | លោក ប៉ូវ វី | អនុប្រធាន | | | |
| | លោកស្រី ខូវ សោភ័ណ | សមាជិក | | | |
| | លោក ស៊ាន បញ្ញា | សមាជិក | | | |
| ត្រួតពិនិត្យដោយ | លោកជំទាវ ស៊ាង សុផល្លា | | | | |
| ឯកភាពដោយ | ឯកឧត្តម ប៊ិច សុខា | | | | |